# II- រាជរដ្ឋាភិបាល

## អនុក្រឹត្យ

### អនុក្រឹត្យលេខ ២២ អនក្រ/បក

### ស្តីពីការរៀបចំឯកសណ្ឋាន និង សក្តិ

### របស់កម្មសិក្សា នាយទាហាន

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង សហអគ្គមេបញ្ជាការនៃកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា
- យោងតាមមាត្រា ៥ នៃអនុក្រឹត្យលេខ ០៤ អនក្រ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ ១៩៩៤ ស្តីពីឯកសណ្ឋាន បច្ចេកទេស និង ទង់ជ័យកងយោធពលខេមរភូមិន្ទ ,
- យោងតាមអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ ១៩៩៤ ស្តីពីការកែតំរូវ និង បំពេញ បន្ថែមតាមអនុក្រឹត្យលេខ ០៤ អនក្រ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៣ របស់រាជរដ្ឋាភិបាលបណ្តោះអាសន្ន
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការពារជាតិ និង អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ

**សំរេច**

**មាត្រា ១.**_ ត្រូវបានរៀបចំឯកសណ្ឋានរបស់កម្មសិក្សា នាយទាហាន មានដូចខាងក្រោម :

**ក- ឯកសណ្ឋាន :**

ឯកសណ្ឋានអាវដៃវែង និង ខោជើងវែង ពណ៌ត្រែអ៊ី ពាក់មួកបេរេ ពណ៌ត្រែអ៊ី ហើយពាក់ស្បែកជើងស្បែក ពណ៌ខ្មៅ កខ្លី ស្រោមជើង ពណ៌ខ្មៅ ។

**រូបភាពនិង ម៉ូត**

-អាវដៃវែង កឧប ប៉ូលស្មា ហោប៉ៅពីរ ខាងលើមានគំរបដូចស្លឹកពោធិ៍ ចំកណ្តាលហោប៉ៅមានដេរផ្នត់ប៉ូល កាត់ស្រុងវែង ដាក់ក្នុងខោ ដៃអាវឆែក ដាក់ឡេវ ពណ៌ត្រែអ៊ី ។

www.pheakdeylaw.com

-ខោចង្កេះ គ្មានជីបខ្លី ហោប៉ៅខោខាងក្រោយពីរគ្មានគម្រប មានដំរបផ្លិតហៅតី និង ហោប៉ៅពីរទៀតបង្កប់តាមថ្នេរចំហៀងរបស់ខោ កាត់ជើងវែង នៅថ្នេរចំហៀងខោ មានឆ្នូត ក្រហមឆ្មារ តាមបណ្តោយខោ ហើយទទឹងខោ ឆ្នូតប្រវែង ២ ស.ម ហើយផ្ទាត់ស៊ើរគែនីយ៍ មានឆ្នូតក្រហមពីរ ចំរូសឆ្នូតម្ខាងៗប្រវែង ១ ស.ម ។

-ស្បែកជើង ពណ៌ត្នោតអី ក្បាលស្បែកជើង ពាក់ ធ្វើពីស្បែកពោត ។

ខ- **មួកបារ៉េ** : មួកបារ៉េ កាត់ដូចមួកកោងរង៉ែតជើងគោក ហើយឆ្នូតលើមួកកោងរង៉ែ តាមកងអន្តរាគមន៍ ។ ពាក់ផ្លាកឈ្មោះ លើហោប៉ៅស្តាំ និង រូបមនុស្សរៀកឡេវហោប៉ៅស្តាំ ដូចទ័ពជើងគោក ។

គ- **សក្តិ** : សក្តិស្លា ដែលមានផ្ទៃប្លង់ ពណ៌ខ្មៅ ក្បាលក្រូច នៅខាងលើប្លង់សក្តិ មានរូបអុជ ទ្រព្រះខ័ន្ធរូបអាយ៉ៃរ និង សរសេរអក្សរកាត់ ឈ្មោះកម្មសិក្សាដូចជា :

+និស្សិត នាយទាហានសកម្ម សរសេរអក្សរកាត់ (ន.ន.ស)

+កម្មសិក្សា នាយទាហានជាន់ទាប សរសេរអក្សរកាត់ (ក.ន.ទ)

+កម្មសិក្សា នាយទាហានជាន់ខ្ពស់ សរសេរអក្សរកាត់ (ក.ន.ខ)

**រូបភាព និង ម៉ូត**

**រូបភាពឃុំសក្តិ** : មានរាងទ្រវែង ចុងស្រួច ធ្វើពីក្រណាត់កាំម៉ី ពណ៌ខ្មៅ នៅលើប្លង់ មាន ឡេវរូបព្រះសង្ហាររូបអុជទ្រព្រះខ័ន រូបអាយ៉ៃរ និង ឈ្មោះកាត់របស់វគ្គកម្មសិក្សា ។

អំពីខ្នាត :

- បណ្តោយប្រវែង ១៣.៥ស.ម
- ទទឹងខាងដើម ៦.០ ស.ម
- ទទឹងខាងចុង ៤.០ ស.ម
- ឡេវមានព្រះសង្ហារ បន្ទាត់ផ្ចិត(ពណ៌មាស) ១.៥ ស.ម
- ពីឡេវទៅចុងស្រួច • ១.០ ស.ម
- អុជ និង ព្រះខ័ន មានទំហំ(ពណ៌សរ) ៣.២ ស.ម
- រូបអាយ៉ៃរ ប្រវែង (ពណ៌មាស) ៦.៣ ស.ម
- ពីដើមប្លង់មកអក្សរ ១.០ ស.ម
- អក្សរសរសេរ កំពស់ទំហំ (ពណ៌មាស) ១.០ ស.ម

**មាត្រា ២.**_ ត្រូវបានកំណត់អំពីការស្លៀកពាក់ ឯកសណ្ឋាន សំរាប់ជើរចេញក្រៅសាលា របស់កម្មសិក្សា នាយទាហានដូចខាងក្រោម ៖

- ចំពោះផលិតផលឱសថបុរាណនាំចូលពីបរទេស ដែលបានចុះបញ្ជីលក់រួចហើយ បណ្តោះអាសន្ន អាចការពារបាន ក្នុងរយៈពេលពីមួយឆ្នាំឡើងទៅ ហើយជាវត្ថុបណ្តោះបណ្តាលទោសទាយការគ្រប់ ប្រភេទ ។ មិនបានអនុញ្ញាតផ្តល់ឲ្យ ឬលក់ចំពោះអាហារូបករណ៍ ដែលមិនកំពុងរៀនសូត្រ និង សិក្សាវត្តហ៊ែន ។

- កម្មសិទ្ធិអាហារូបករណ៍ត្រូវស្នើរកាត់ឯកសារប្រវត្តិនេះ តាមការកំណត់របស់គណៈ និង កាត់ពេលចេញជើងតំរែរការក្រុមគណៈ ។ ចំពោះកម្មសិទ្ធិបុគ្គល ដែលរៀនសូត្រចប់វគ្គ សិក្សាមិនអនុញ្ញាតឲ្យកាត់ឯកសារប្រវត្តិ និង រូបសណ្ឋាននេះឡើយ ។

- **ការស្នើរកាត់ :** ស្នើរកាត់ឯកសារប្រវត្តិនេះ ត្រូវកាត់មួយតាមនេះ សញ្ញាលើការ តាមជំនាញសិល្បៈកម្មសិទ្ធិ ផ្កាឈ្មោះ លើលើលកជើស្នាំ (ដូចផ្កាឈ្មោះឯកសារប្រវត្តិការងារ) រូបមនុស្ស បន្ទោករឿងលកជើស្នាំសញ្ញាសំគាល់វគ្គសិក្សា ឬ មេដែកលកជើឆ្វេង នៅជើងដៃអាវ សស្តាំ មានកាត់ផ្កាកងលកពណ៌មាសភូមិន្ទ និង ស្បែកជើង ពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ ។

មាត្រា ៣ .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយកឧត្តមសេនាធិការ នៃកងយោធពលខេមរភូមិន្ទ និង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ។

មាត្រា ៤ . អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិង ត្រា

**អ៊ឹង ហួត** **ហ៊ុន សែន**

***

**អនុក្រឹត្យលេខ ២៣ អនក្រ/បក**

**ស្តីពីផលិតកម្ម អាហរណ៍-នីហរណកម្ម និង ពាណិជ្ជកម្ម**

**ឱសថបុរាណសំរាប់វិស័យសុខាភិបាល**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២

www.pheakdeylaw.com